ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ០៥៨ ប្រក

ថ្ងៃព្រហស្បតិ៍ ៣ កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២២

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់អនុវត្តក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ សម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ ._**

ត្រូវបានដាក់ឱ្យអនុវត្តក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដើម្បីអភិវឌ្ឍ និងលើកកម្ពស់តម្លៃបុគ្គល និងវិជ្ជាជីវៈរបស់បុគ្គលិកនីមួយៗ តាមរយៈការប្រតិបត្តិវិជ្ជាជីវៈប្រកបដោយសីលធម៌ និងសេចក្តីថ្លៃថ្នូរ ក្នុងគោលដៅអភិវឌ្ឍស្តង់ដារ និងគុណភាពអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ និងបង្កើនធនធានសិស្ស/សិក្ខាកាមទាំងគុណភាព និងបរិមាណក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ ._**

គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងអស់ ត្រូវរៀបចំឱ្យមានក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់គ្រឹះស្ថានរបស់ខ្លួន ផ្អែកលើក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ ._**

គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងបុគ្គលិកនៃគ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងអស់ ត្រូវអនុវត្តក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នេះឱ្យបានខ្ជាប់ខ្ជួន។

**ប្រការ៤ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥. _**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយិកាវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ ប្រធាននាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ គ្រប់ប្រធានអង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត និងគ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ត្រូវទទួលអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់អនុបផ្ទក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ សម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

រាជធានីភ្នំពេញ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២២

# ក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ

# របស់ [ឈ្មោះគ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍]

**សេចក្តីសង្ខេប**

[សម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នីមួយៗតាក់តែងរៀងៗខ្លួន]

# ក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ

## សម្រាប់បុគ្គលិករបស់

## [ឈ្មោះគ្រឹះស្ថានបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍]

## 1. គោលបំណង

១.1. ក្រមនេះ មានគោលបំណងកំណត់អំពី និងដាក់ឱ្យប្រើប្រាស់នូវ ក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ របស់បុគ្គលិកសាលាបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍ និងលើកកម្ពស់តម្លៃបុគ្គល និងវិជ្ជាជីវៈរបស់បុគ្គលិកនីមួយៗ តាមរយៈការប្រតិបត្តិវិជ្ជាជីវៈប្រកបដោយសីលធម៌ និងសេចក្តីថ្លៃថ្នូរ ក្នុងគោលដៅអភិវឌ្ឍស្តង់ដារ និងគុណភាពអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ និងបង្កើនធនធានសិស្ស/សិក្ខាកាមទាំងគុណភាព និងបរិមាណក្នុងព្រះរាជាណាចក្រកម្ពុជា។

១.2. ក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ សម្រាប់បុគ្គលិកផ្នែកបណ្តុះបណ្តាល និងសម្រាប់បុគ្គលិកផ្នែកផ្សេង មានចែងជារៀងគ្នាជា ឧបសម្ព័ន្ធទី ១ និង ឧបសម្ព័ន្ធទី ២ នៃក្រមនេះ។

## 2. វិសាលភាព

ក្រមនេះ កំណត់អំពីគោលការណ៍ និងវិធានសីលធម៌ និងការប្រតិបត្តិវិជ្ជាជីវៈ បន្ថែមលើវិធានអប្បបរមា ដែលកំណត់ដោយច្បាប់ជាធរមាន និងក្រមសីលធម៌វិជ្ជាជីវៈ និង/ឬក្រមប្រតិបត្តិវិជ្ជាជីវៈប្រសិនបើមាន ដែលកំណត់ដោយច្បាប់។ ក្នុងករណីមានចំណុចខ្វែង វិធានអប្បបរមា នៃច្បាប់ជាធរមាន និងក្រមសីលធម៌វិជ្ជាជីវៈ និង/ឬក្រមប្រតិបត្តិវិជ្ជាជីវៈកំណត់ដោយច្បាប់ ត្រូវមានឧត្តមានុភាព។

## 3. ការកែប្រែក្រម

គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នឹងត្រួតពិនិត្យក្រមនេះជាទៀងទាត់ ដើម្បីធានាការធ្វើបច្ចុប្បន្នភាពឱ្យទាន់ពេលវេលាស្របតាម ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ក៏ដូចជានិន្នាការ និងតម្រូវការជាក់ស្តែង។ សម្រាប់គោលបំណងនេះ គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ អាចរៀបចំឱ្យមានការស្ទង់មតិ និងការពិភាក្សា ដើម្បីទទួលបានមតិយោបល់អំពីការអនុវត្តកន្លងមក ចំណុចដែលត្រូវពិចារណា និងដាក់សំណើកែប្រែក្រមសម្រាប់ពិភាក្សាជាដើម។

## 4. ការរាយការណ៍អំពីកំហុស

៤.1. ដើម្បីរាយការណ៍អំពីករណីរំលោភបំពានលើបទប្បញ្ញត្តិណាមួយនៃក្រមនេះ ឬការសង្ស័យថាមានករណីរំលោភបំពាន សូមទាក់ទងមកកាន់៖

- លេខទូរស័ព្ទ៖ [*]។
- អ៊ីមែល៖ [*]។

៤.2. រាល់ការរាយការណ៍ទាំងឡាយដែលបានធ្វើឡើងក្រោមប្រការ ៤.1 ខាងលើ ដោយសុចរិត និងមិនបំភ្លៃការពិត អត្តសញ្ញាណរបស់បុគ្គលរាយការណ៍នោះ នឹងត្រូវរក្សាជាការសម្ងាត់ ហើយទទួលបានការរួចផុតពីការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈ ប្រសិនបើការរាយការណ៍នោះ បង្កើតឱ្យមានការទទួលខុសត្រូវណាមួយផ្នែកវិជ្ជាជីវៈរបស់បុគ្គលរាយការណ៍។

## 5. ទណ្ឌកម្មវិន័យ

៥.1. រាល់ការអនុវត្តវិជ្ជាជីវៈរបស់បុគ្គលិកសាលាបណ្តុះបណ្តាល ដែលមិនគោរព និងអនុវត្តតាមបទប្បញ្ញត្តិរបស់ក្រមនេះ ត្រូវបានស៊ើបអង្កេតដោយ ក្រុមប្រឹក្សាវិន័យរបស់សាលាបណ្តុះបណ្តាល ក្នុងករណីទទួលបានការរាយការណ៍ដូចករណីប្រការ ៤ ខាងលើ ឬតាមការផ្តួចផ្តើមរបស់ក្រុមប្រឹក្សាវិន័យរបស់សាលាបណ្តុះបណ្តាល។

៥.2. ក្រោយការស៊ើបអង្កេត និងការសាកសួរនានា ក្រុមប្រឹក្សាវិន័យ ត្រូវចេញសេចក្តីសម្រេច រួមទាំងទណ្ឌកម្មវិន័យ ដែលត្រូវអនុវត្ត (ប្រសិនបើត្រូវអនុវត្ត)។ ក្នុងករណីមិនរាងចាល ក្រោយពីបានទទួលការស្តីបន្ទោស ឬលិខិតព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ បុគ្គលិកដែលប្រព្រឹត្តខុសនោះ អាចនឹងត្រូវទទួលទណ្ឌកម្មវិន័យផ្សេងទៀត ដូចមានកំណត់ក្នុង ប្រការ ៥.3។

៥.3. ផ្អែកតាមកម្រិតនៃកំហុសនីមួយៗ និងការខូចខាតដែលបណ្តាលមកពីកំហុសនោះ ក្រុមប្រឹក្សាវិន័យអាចសម្រេចដាក់ទណ្ឌកម្មវិន័យនានាខាងក្រោម៖

- ការស្តីបន្ទោស
- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្ទេរទៅមុខតំណែងផ្សេង (ក្នុងកម្រិតប្រាក់ខែដដែល ឬទាបជាង)
- ការកាត់បន្ថយប្រាក់ខែ ឬបញ្ចុះកម្រិតតួនាទីជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍
- ការផ្អាកកិច្ចសន្យាការងារជាបណ្តោះអាសន្ន
- ការបញ្ចប់កិច្ចសន្យាការងារ។

## 6. យន្តការវាយតម្លៃ (Assessment Tools)

សាលាបណ្តុះបណ្តាល អាចរៀបចំដាច់ទៀងទាត់ឱ្យមានការស្ទង់មតិ ការវាយតម្លៃជាលាយលក្ខណ៍អក្សរ ឬជាការពិភាក្សាលើ ខ្លឹមសារ និងការអនុវត្តក្រម (ឧទាហរណ៍៖ រៀបចំឱ្យមានការវាយតម្លៃជារៀងរាល់ឆ្នាំ)។ ជារឿយៗ បុគ្គលិកសាលាបណ្តុះបណ្តាល ត្រូវស្វ័យវាយតម្លៃយ៉ាងតឹងរ៉ឹងលើការប្រតិបត្តិសីលធម៌ និងវិជ្ជាជីវៈរបស់ខ្លួន ក៏ដូចជាផ្តួចផ្តើម ឬចូលរួមយ៉ាងសកម្មក្នុងការវាយតម្លៃលើការអនុវត្តក្រម ប្រសិនបើមានការរៀបចំដោយសាលាបណ្តុះបណ្តាល។

## 7. អវសានប្បញ្ញត្តិ

៧.1. ក្រមនេះ ត្រូវមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

៧.2. ក្រមនេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ និងភាសាអង់គ្លេស។ ក្នុងករណីមានភាពខុសគ្នារវាងភាសាទាំងពីរ ឯកសារជាភាសាខ្មែរ ត្រូវមានឧត្តមានុភាព។

៧.3. គោលការណ៍ប្រតិបត្តិស្តង់ដារសម្រាប់ដំណើរការគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលក្នុងបរិបទកូវីដ-១៩ បុគ្គលិកសាលាបណ្តុះបណ្តាល ត្រូវ៖

- ជំរុញ និងដាក់បញ្ចូលក្នុងការអប់រំនូវការព្រមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ តាមរយៈការរៀនរស់នៅក្នុងគន្លងប្រក្រតីភាពថ្មី និងការជំរុញឱ្យមានការប្រកាន់ខ្ជាប់នូវវិធានការនានា ដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ដូចជាវិធានការ «៣កុំ ៣ការពារ» ជាដើម។

- ចូលរួមសហការជាមួយសាលាបណ្ដុះបណ្ដាល និងអនុវត្តអោយបានខ្ជាប់ខ្ជួននូវគោលការណ៍ប្រតិបត្តិស្តង់ដារ (SOP) ទាំងអស់ ដែលជាឯកសារណែនាំអំពីផែនការសុខាភិបាលសម្រាប់គ្រឹះស្ថានសិក្សានីមួយៗ រៀបចំ និងត្រៀមលក្ខណៈដំណើរការ ការបង្រៀន និងការរៀនឡើងវិញ ក៏ដូចជាបន្តអភិវឌ្ឍសាលាបណ្ដុះបណ្ដាលប្រកបដោយនិរន្តរភាព ដើម្បីធានាឱ្យបាននូវលក្ខខណ្ឌសុវត្ថិភាព និងសុខភាពនៅសាលាបណ្ដុះបណ្ដាល សម្រាប់សិស្ស/សិក្ខាកាម មាតាបិតា ក៏ដូចជាបុគ្គលិកផ្នែកបណ្ដុះបណ្ដាល និងបុគ្គលិកផ្នែកផ្សេង ក្នុងបរិបទកូវីដ-១៩ និងនាពេលអនាគត និង
- តាមដានឱ្យបានជាប់លាប់នូវ ការកែប្រែ ឯកសារថ្មី ឬបន្ថែមណាមួយ ដែលចេញពាក់ព័ន្ធនឹងគោលការណ៍ប្រតិបត្តិរបស់សាលាបណ្ដុះបណ្ដាលនៅក្នុងបរិបទកូវីដ-១៩។

៧.4. វាក្យស័ព្ទសំខាន់ៗ ដែលប្រើក្នុងក្រមនេះ និងតំណភ្ជាប់ទៅឯកសារយោងនានា (ឧទាហរណ៍៖ គោលការណ៍ប្រតិបត្តិស្តង់ដារសម្រាប់ដំណើរការសាលាបណ្ដុះបណ្ដាលក្នុងបរិបទកូវីដ-១៩) មានភ្ជាប់រៀងគ្នាជាឧបសម្ព័ន្ធទី ៣ និងឧបសម្ព័ន្ធទី ៤ នៃក្រមនេះ។

៧.5. សម្រាប់ព័ត៌មានបន្ថែម និងមតិយោបល់នានាអំពីក្រម សូមទាក់ទងមកកាន់៖

- លេខទូរស័ព្ទ៖ [*]។
- អ៊ីមែល៖ [*]។

..................ថ្ងៃទី.........ខែ............ឆ្នាំ២០២......

**ហត្ថលេខា និងត្រា**

**ឈ្មោះហត្ថលេខី**

**មុខតំណែង**

**ចម្លងជូន៖**

- [*]
- [*]
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ១៖ ក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ

# សម្រាប់បុគ្គលិកផ្នែកបណ្ដុះបណ្ដាល

# ផ្នែក ក៖ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិកផ្នែកបណ្តុះបណ្តាល

---

## 1. គោលបំណង

ក្រមសីលធម៌វិជ្ជាជីវៈនេះ មានគោលបំណងកំណត់ និងណែនាំអំពីគោលការណ៍ជាគុណតម្លៃស្នូល ដែលជាមូលដ្ឋានគ្រឹះនៃអត្តចរិត ការសម្រេចចិត្ត សកម្មភាព ការរៀបចំបុគ្គលិកលក្ខណៈ និងការសំដែងអាកប្បកិរិយា ប្រកបដោយសីលធម៌វិជ្ជាជីវៈក្នុងគោលដៅលើកកម្ពស់តម្លៃបុគ្គល និងតម្លៃវិជ្ជាជីវៈក្នុងនាមជាអ្នកអប់រំជំនាញ។

## 2. គោលការណ៍ជាគុណតម្លៃស្នូល

### 2.1. សមភាព

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវបង្ហាញ **សមភាព** តាមរយៈការផ្តល់តម្លៃស្មើៗគ្នាចំពោះបុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈរបស់ខ្លួន ក៏ដូចជាចូលរួមបង្កើតបរិយាកាសសមភាពក្នុងមជ្ឈដ្ឋានអប់រំ ដោយមិនមាន ការរើសអើង និន្នាការចិត្តប្រកាន់ ឬបុរេនិច្ច័យណាមួយឡើយ។

### 2.2. សុចរិតភាព

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវបង្ហាញ **សុចរិតភាព** តាមរយៈ៖

- ភាពស្មោះត្រង់ ទង្វើត្រឹមត្រូវ និងការប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ និងតម្លាភាព ក្នុងការបំពេញវិជ្ជាជីវៈ
- ការកសាងទំនុកចិត្ត ក្នុងទំនាក់ទំនងជាមួយបុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈ (ឧទាហរណ៍៖ ការកសាងបរិយាកាសនៃអារម្មណ៍សុវត្ថិភាព ក្នុងក្របខណ្ឌដែលបុគ្គលិកផ្នែកបណ្តុះបណ្តាល ក្លាយជាបុគ្គលម្នាក់ ដែលបុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈ អាចចែករំលែក ដោះដូរ យោបល់ និងពិភាក្សាស្វែងរកដំបូន្មាន ដោយទុកចិត្ត និងមិនមានការបារម្ភអ្វីឡើយ) និង
- ឆន្ទៈដ៏រឹងមាំ និងមិនងាករេ ក្នុងការផ្សារភ្ជាប់ខ្លួននឹងគោលការណ៍ និងគុណតម្លៃនៃសីលធម៌វិជ្ជាជីវៈ ក៏ដូចជាការប្រកាន់ជំហរក្នុងការអនុវត្តតាម និងលើកតម្កើងជាផលបន្សំគោលការណ៍ និងគុណតម្លៃនៃសីលធម៌វិជ្ជាជីវៈទាំងនោះ នៅគ្រប់កាលៈទេសៈទាំងអស់។

### 2.3. ទំនួលខុសត្រូវ

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវបង្ហាញ **ទំនួលខុសត្រូវ** តាមរយៈ៖

- ការឱ្យអាទិភាពដល់ការអភិវឌ្ឍស្នូលជារ និងគុណភាពនៃការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងការផ្តល់សេវាអប់រំសម្រាប់គ្រប់សិស្ស/សិក្ខាកាមរបស់សាលាបណ្តុះបណ្តាលដោយគោរពតាមក្របខណ្ឌគុណវុឌ្ឍិជាតិ និង/ឬ វិជ្ជាជីវៈទេសចរណ៍ជាតិ និងអាស៊ាន
- ការផ្តួចផ្តើម និងការផ្សារភ្ជាប់ខ្លួននឹងការអភិវឌ្ឍ វិជ្ជាជីវៈ សមត្ថភាព និងសេវាក្នុងការអប់រំជំនាញទេសចរណ៍ឱ្យកាន់តែប្រសើរឡើង និង
- ការបំពេញការងារក្នុងស្មារតីសហការជាមួយបុគ្គលិកសាលាបណ្តុះបណ្តាល ក៏ដូចជាបុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈ ដើម្បីផលប្រយោជន៍ល្អបំផុតរបស់សិស្ស/សិក្ខាកាម និងសាលាបណ្តុះបណ្តាល។

2.4. **គណនេយ្យភាព**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវបង្ហាញ **គណនេយ្យភាព** តាមរយៈ៖

- ការកំណត់គោលដៅដែលជាក់លាក់ និងអាចសម្រេចបានណាមួយ ព្រមជាមួយនឹងផែនការសកម្មភាព ដែលត្រូវ បំពេញដើម្បីសម្រេចគោលដៅនោះ និង
- ភាពម្ចាស់ការលើសកម្មភាព រួមមានការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងចេញមុខទទួលខុសត្រូវចំពោះផែនការសកម្មភាពរបស់ខ្លួន និងលទ្ធផលរបស់វា មិនថាជាលទ្ធផលល្អ ឬអាក្រក់។

2.5. **ឯករាជ្យភាព និងភាពមិនលម្អៀង**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវបង្ហាញ **ឯករាជ្យភាព និងភាពមិនលម្អៀង** តាមរយៈ៖

- ផ្តល់ការអប់រំ មិនថាការពន្យល់ ការផ្តល់ឱកាសបាញ្ចេញស្នាដៃ ការសាកសួរ ការឆ្លើយតប ការដាស់តឿន ការជំរុញលើកទឹកចិត្ត ដល់គ្រប់សិស្ស/សិក្ខាកាមទាំងអស់ស្មើៗគ្នា ដោយមិនមានការយកចិត្តទុកដាក់ជាពិសេសចំពោះសិស្ស/សិក្ខាកាមណាម្នាក់ឡើយ
- ការឱ្យយោបល់ ការណែនាំ ការសម្រេចចិត្ត ឬការវិនិច្ឆ័យដោយគម្លាភាពលើ ការសិក្សា ឬស្ថានភាពកំហុសរបស់សិស្ស/សិក្ខាកាមនីមួយៗ ដោយផ្អែកលើគតិ ការថ្លឹងថ្លែង ការពិត សាក្សី និងភស្តុតាងជាក់ស្តែង ដោយមិនមានការវិនិច្ឆ័យទុកជាមុនណាមួយ ឬរងឥទ្ធិពលពីកត្តា ហេតុការណ៍ ឬបុគ្គលណាម្នាក់ៗ និង
- ការមិនបណ្តោយឱ្យគំនិត ទស្សនៈ ឬបទពិសោធន៍ផ្ទាល់ខ្លួន ប៉ះពាល់ដល់ការបំពេញមុខងារ ការវិនិច្ឆ័យ ឬការសម្រេចចិត្ត។

2.6. **ការគោរពចំពោះអ្នកដទៃ**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវបង្ហាញ **ការគោរពចំពោះអ្នកដទៃ** មិនថាជាពាក្យសំដី ឬសកម្មភាព តាមរយៈការឱ្យតម្លៃគ្នាទៅវិញទៅមក និងការប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ ក្នុងទំនាក់ទំនងជាមួយ សិស្ស/សិក្ខាកាម មាតាបិតា មិត្តរួមការងារជាបុគ្គលិកផ្នែកបណ្តុះបណ្តាលដូចគ្នា ឬបុគ្គលដទៃទៀត។

3. **ការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវវិជ្ជាជីវៈ**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវមានការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវវិជ្ជាជីវៈចំពោះ សិស្ស/សិក្ខាកាម មាតាបិតា សហគមន៍ បុគ្គលិកសាលាបណ្តុះបណ្តាល សាលាបណ្តុះបណ្តាល និងវិជ្ជាជីវៈ ដោយឈរលើគោលការណ៍សមភាព សុចរិតភាព ទំនួលខុសត្រូវ គណនេយ្យភាព ឯករាជ្យភាព និងភាពមិនលម្អៀង និងការគោរពចំពោះអ្នកដទៃ។ បុគ្គលិកផ្នែកបណ្តុះបណ្តាល ក៏ត្រូវឈរលើស្មារតីយោគយល់ អត់ឱន និងសាមគ្គីភាព ដើម្បីសម្រុះសម្រួល និងដោះស្រាយដោយសន្តិវិធី ក្នុងករណីមានជម្លោះជាមួយបុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈ។

3.1. **ចំពោះសិស្ស/សិក្ខាកាម**

សិស្ស/សិក្ខាកាម និងផលប្រយោជន៍ល្អបំផុតរបស់ពួកគេគឺជាអាទិភាពរបស់បុគ្គលិកផ្នែកបណ្តុះបណ្តាល។ សម្រាប់គោលបំណងនេះ បុគ្គលិកផ្នែកបណ្តុះបណ្តាលត្រូវ៖

- ប្រកបដោយគុណសម្បត្តិ យកចិត្តទុកដាក់បង្រៀន ពន្យល់ បកស្រាយ និងចែករំលែកចំណេះដឹងដល់សិស្ស/សិក្ខាកាម ស្របតាមមុខវិជ្ជា និងឯកទេសរបស់ខ្លួន ដោយគោរពតាមក្របខណ្ឌគុណវុឌ្ឍិជាតិ និង/ឬ វិជ្ជាជីវៈទេសចរណ៍ជាតិ និងអាស៊ាន ដោយសមភាព និងមិនរើសអើង
- ជំរុញលើកទឹកចិត្តសិស្ស/សិក្ខាកាមឱ្យគោរពបទបញ្ជាផ្ទៃក្នុងរបស់សាលាបណ្តុះបណ្តាល ចេះសិក្សាដោយមានទំនួលខុសត្រូវ និងគោរពគ្នាទៅវិញទៅមក
- បណ្តុះបណ្តាល និងថែរក្សាទំនាក់ទំនងល្អជាមួយសិស្ស/សិក្ខាកាម
- រក្សាព័ត៌មានដែលទទួលបានពីសិស្ស/សិក្ខាកាមជាការសម្ងាត់
- ឆ្លើយតបចំពោះស្ថានភាពពាក់ព័ន្ធនឹងសិស្ស/សិក្ខាកាម មិនថាជាសកម្មភាព ឬឥរិយាបថ ក្នុងន័យវិជ្ជមាន និងមានស្មារតីស្វែងរកដំណោះស្រាយល្អបំផុតសម្រាប់សិស្ស/សិក្ខាកាម និង
- ឈរលើគោលការណ៍យុត្តិធម៌ និងតម្លាភាព ដាក់វិន័យសិស្ស/សិក្ខាកាម តាមគោលការណ៍ វិធាន ឬបទបញ្ជាផ្ទៃក្នុងរបស់សាលាបណ្តុះបណ្តាល ក្រោយពីបានសាកសួរ និងស៊ើបអង្កេតច្បាស់លាស់។

3.2. **ចំពោះមាតាបិតា**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវ៖

- បណ្តុះបណ្តាល និងថែរក្សា ទំនាក់ទំនងល្អជាមួយមាតាបិតា
- ផ្តល់ការប្រឹក្សា ឱវាទ និងការណែនាំដល់មាតាបិតា ចែករំលែកព័ត៌មានត្រឹមត្រូវ និងពិតប្រាកដអំពីសកម្មភាព ស្ថានភាព វឌ្ឍនភាព និងលទ្ធផលនៃការសិក្សារបស់សិស្ស/សិក្ខាកាម
- ណែនាំ និងផ្តល់ដំណោះស្រាយ ក្រោយពីបានស្តាប់ មតិយោបល់ ការយល់ឃើញ ឬការបារម្ភដែលលើកឡើងដោយមាតាបិតា និង
- មិនបង្ខិតបង្ខំមាតាបិតា ឱ្យផ្តល់អត្ថប្រយោជន៍ទោះក្រោមរូបភាពណាក៏ដោយ។

3.3. **ចំពោះសហគមន៍**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវចូលរួម គាំទ្រគ្រប់សកម្មភាពអប់រំ ផ្តល់សេវាអប់រំប្រកបដោយស្តង់ដារ និងគុណភាព ក៏ដូចជាចូលរួមចំណែកកសាងទំនុកចិត្តពីសាធារណជន និងជំរុញការគាំទ្រពីសហគមន៍ចំពោះការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

3.4. **ចំពោះបុគ្គលិកសាលាបណ្តុះបណ្តាល**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវបណ្តុះបណ្តាល និងថែរក្សាទំនាក់ទំនងល្អជាមួយបុគ្គលិកសាលាបណ្តុះបណ្តាលដោយមិនប្រកាន់ឋានានុក្រមការងារ ព្រមទាំងផ្តួចផ្តើម សហការ ផ្សព្វផ្សាយ ចែករំលែក ដោះដូរ ចំណេះដឹង និងបទពិសោធន៍។

3.5. **ចំពោះសាលាបណ្តុះបណ្តាល**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវ៖

- គោរព និងបំពេញតួនាទី ភារកិច្ចរបស់ខ្លួនស្របតាមវិសាលភាពការងារ ដែលបានព្រមព្រៀង
- ប្រកាន់ខ្ជាប់ និងគោរពតាមស្មារតី កម្មវត្ថុ ទស្សនៈវិស័យ បេសកកម្ម គោលនយោបាយវិធានរបស់សាលាបណ្តុះបណ្តាលនៅគ្រប់រាល់សកម្មភាពវិជ្ជាជីវៈទាំងអស់របស់ខ្លួន

- ផ្តួចផ្តើម និងចូលរួមយ៉ាងសកម្មក្នុង ការបញ្ចេញមតិយោបល់ និងផ្តល់ការវាយតម្លៃច្បាស់លាស់ លើផែនការ គោលនយោបាយ ឬផែនការរបស់សាលាបណ្តុះបណ្តាល
- ពង្រឹង និងអភិវឌ្ឍសមត្ថភាពរបស់សាលាបណ្តុះបណ្តាល តាមរយៈការស្នើផែនការសកម្មភាពច្បាស់លាស់ រួមទាំងសហការ និងអនុវត្តយន្តការផ្សេងទៀត ដើម្បីធានាគុណភាពអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលកំណត់ដោយក្រសួងទេសចរណ៍ និង/ឬ ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត និង
- ជៀសវាងការប្រព្រឹត្តទង្វើ ដែលអាចធ្វើឱ្យអាប់ឱន ប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់សាលាបណ្តុះបណ្តាលក្នុងមជ្ឈដ្ឋានអប់រំ សហគមន៍ ក៏ដូចជាចំពោះសាធារណជន។

3.6. **ចំពោះវិជ្ជាជីវៈ**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវ៖

- ឱ្យអាទិភាពដល់ការអភិវឌ្ឍស្តង់ដារ និងគុណភាពនៃការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ គ្រប់ទម្រង់ មិនថាជាការសិក្សាក្នុងថ្នាក់ តាមប្រព័ន្ធអនឡាញ និង/ឬជាការសិក្សាតាមមធ្យោបាយផ្សេងទៀត
- យល់ដឹងអំពីភាពចាំបាច់ និងសារៈសំខាន់ នៃភារកិច្ច និងការបំពេញមុខនាទីរបស់ខ្លួនប្រកបដោយសីលធម៌ និងវិជ្ជាជីវៈ ក៏ដូចជាផលប៉ះពាល់ដែលអាចកើតចេញពីឱនភាពនៃការប្រតិបត្តិមិនបានត្រឹមត្រូវ ដែលនឹងជាកញ្ចក់ឆ្លុះបញ្ចាំងដោយផ្ទាល់អំពី តម្លៃ គុណភាព និងប្រសិទ្ធភាពនៃការបំពេញវិជ្ជាជីវៈ និងមុខនាទីជាអ្នកអប់រំរបស់ខ្លួន
- ជៀសវាងការប្រព្រឹត្តអំពើទាំងឡាយណា ដែលធ្វើឱ្យអាប់ឱន ប៉ះពាល់ដល់វិជ្ជាជីវៈ កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួន និងចេញមុខទទួលខុសត្រូវ នៅពេលប្រព្រឹត្តកំហុស
- ផ្តួចផ្តើម និងផ្សារភ្ជាប់ខ្លួននឹងការអភិវឌ្ឍ វិជ្ជាជីវៈ សមត្ថភាព និងសេវាក្នុងការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍
- ផ្តល់ឯកសារ និងព័ត៌មានពិតប្រាកដអំពី កម្រិតចំណេះដឹង ជំនាញ និងបទពិសោធន៍ដែលខ្លួនមានពាក់ព័ន្ធនឹងវិជ្ជាជីវៈ ដោយមិនបំភ្លៃ ឬលាក់លៀម
- បន្តខិតខំប្រឹងប្រែង គាំទ្រ លើកតម្កើង និងផ្តល់អាទិភាពចំពោះ តម្លៃ និងកិត្តិយសវិជ្ជាជីវៈ ក៏ដូចជាស្តង់ដារ និងគុណភាពអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍
- បន្តស្វ័យសិក្សា ពង្រីកចំណេះដឹង និងពង្រឹងសមត្ថភាព ផ្តួចផ្តើម សហការ ផ្សព្វផ្សាយ ចែករំលែក ដោះដូរចំណេះដឹង និងបទពិសោធន៍ ដើម្បីធានាបាននូវការអប់រំបណ្តុះបណ្តាលដែលប្រកបដោយស្តង់ដារ និងគុណភាព
- រៀបចំផែនការ យុទ្ធសាស្ត្រ យន្តការ និងជំហានក្នុងការអប់រំបណ្តុះបណ្តាល និងផែនការបំរុង មិនថាជាទ្រឹស្តី ឬការអនុវត្តផ្ទាល់ដោយគោរពតាមក្របខណ្ឌគុណវុឌ្ឍិជាតិ និង/ឬ វិជ្ជាជីវៈទេសចរណ៍ជាតិ និងអាស៊ាន ដើម្បីបង្កើតមជ្ឈដ្ឋានសិក្សាដ៏ល្អប្រសើរ សម្រាប់ការរីកចម្រើនរបស់សិស្ស/សិក្ខាកាម មិនថាផ្នែក ចំណេះដឹង ជំនាញ ឬអត្តចរិត
- ផ្តល់សេវាក្នុងការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ ប្រកបដោយគុណកោសល្យ ស្របតាមមុខវិជ្ជា និងឯកទេសរបស់ខ្លួន ដោយគោរពតាមក្របខណ្ឌគុណវុឌ្ឍិជាតិ និង/ឬ វិជ្ជាជីវៈទេសចរណ៍ជាតិ និងអាស៊ាន ក៏ដូច

ជាកម្មវិធីបណ្តុះបណ្តាល ដែលត្រូវបានទទួលស្គាល់ ឬកំណត់ដោយក្រសួងទេសចរណ៍ និង/ឬ ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត សម្រាប់ការសិក្សាគ្រប់ទម្រង់ មិនថាជាការសិក្សាក្នុងថ្នាក់ តាមប្រព័ន្ធអនឡាញ និង/ឬជាការសិក្សាតាមមធ្យោបាយផ្សេងទៀត

- រៀបចំឱ្យមានការវាយតម្លៃ និងប្រមូលការវាយតម្លៃ លើការសិក្សារបស់សិស្ស/សិក្ខាកាម និងការអប់រំបណ្តុះបណ្តាលរបស់ខ្លួន ក៏ដូចជាយន្តការសម្រាប់ជំហានបន្ទាប់ ក្រោយមានការវាយតម្លៃ
- ជំរុញឱ្យមាន និងទទួលយក ការបញ្ចេញមតិ ការច្នៃប្រឌិត ការបង្កើតថ្មី ដើម្បីអភិវឌ្ឍស្តង់ដា និងគុណភាពនៃសកម្មភាពវិជ្ជាជីវៈ
- ជំរុញឱ្យមានការប្រើប្រាស់ និងបញ្ចូល បច្ចេកវិទ្យាជាផ្នែកមួយនៃការអប់រំ
- មានភាពបត់បែនក្នុងការផ្តល់សេវាអប់រំ ដែលអាចប្រែប្រួលទៅតាមលក្ខខណ្ឌ/ស្ថានភាពសិក្សារបស់សិស្ស/សិក្ខាកាមនីមួយៗ ដើម្បីផ្សារភ្ជាប់ និងទាក់ទាញចំណាប់អារម្មណ៍សិស្ស/សិក្ខាកាម ចំពោះការសិក្សា
- ផ្តល់ការវាយតម្លៃច្បាស់លាស់ យុត្តិធម៌ និងប្រកបដោយតម្លាភាព លើវឌ្ឍនភាព និងលទ្ធផលនៃការសិក្សារបស់សិស្ស/សិក្ខាកាមនីមួយ
- ែណនាំ ដាស់តឿន និងផ្តល់ដំបូន្មាន ដល់សិស្ស/សិក្ខាកាមក្នុងន័យស្ថាបនា រួមទាំងសរសើរ និងលើកទឹកចិត្តឱ្យមានការភ្ញាក់រលឹកចេះកែប្រែខ្លួនក្រោយប្រព្រឹត្តកំហុស ឬបន្តខិតខំប្រឹងប្រែងសិក្សា
- មានស្មារតីសហការជាមួយ មិត្តរួមការងារដែលជាបុគ្គលិកផ្នែកបណ្តុះបណ្តាលដូចគ្នា ក៏ដូចជាបុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈ ដើម្បីផលប្រយោជន៍ល្អបំផុតរបស់សិស្ស/សិក្ខាកាម និង
- ធ្វើគំរូជាគំរូល្អសម្រាប់មិត្តរួមការងារជាបុគ្គលិកផ្នែកបណ្តុះបណ្តាលដូចគ្នា ឬបុគ្គលដទៃទៀតក្នុងមជ្ឈដ្ឋានអប់រំ ដោយការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈយ៉ាងខ្ជាប់ខ្ជួន ក៏ដូចជាផ្សព្វផ្សាយបន្តអំពីការប្រតិបត្តិមុខងារប្រកបដោយសីលធម៌វិជ្ជាជីវៈ និងផ្តួចផ្តើមការពិភាក្សាអំពីគោលការណ៍នានារបស់ក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីបង្កើនការយល់ដឹង និងជំរុញជា រឿយៗឱ្យមានការអនុវត្ត។

## ផ្នែក ខ៖ ក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់បុគ្គលិកផ្នែកបណ្តុះបណ្តាល

---

### 1. គោលបំណង

ក្រមប្រតិបត្តិវិជ្ជាជីវៈនេះ មានគោលបំណងកំណត់ និងណែនាំអំពីស្តង់ដារសកម្មភាពជាមូលដ្ឋាន ដែលបុគ្គលិកអប់រំរបស់សាលាបណ្តុះបណ្តាល ត្រូវជៀសវាង និងអនុវត្តឱ្យបានខ្ជាប់ខ្ជួនក្នុងសកម្មភាពវិជ្ជាជីវៈ ក្នុងគោលដៅលើកកម្ពស់តម្លៃវិជ្ជាជីវៈ ក៏ដូចជាស្តង់ដារ ប្រសិទ្ធភាព គុណភាព និងទំនុកចិត្តរបស់សាធារណជនចំពោះ ការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍របស់សាលាបណ្តុះបណ្តាល។

### 2. ភាពស័ក្តិសមសម្រាប់វិជ្ជាជីវៈ

បន្ថែមពីលើសមត្ថភាពស្នូល (core competencies) បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវដើរតួជាគំរូល្អក្នុងមជ្ឈដ្ឋានអប់រំ មិនថាតាមរយៈពាក្យសំដី សកម្មភាព ឬការស្លៀកពាក់ ដោយជានិច្ចកាលត្រូវ៖

#### 2.1. ចំណេះ និងជំនាញ

- ឆ្លងកាត់ការបណ្តុះបណ្តាលដោយជោគជ័យ ក៏ដូចជាមានគរុកោសល្យ ចំណេះ និងជំនាញ ក្នុងការប្រកបវិជ្ជាជីវៈ
- បន្តស្វ័យសិក្សា ពង្រីកចំណេះដឹង និងពង្រឹងសមត្ថភាព ផ្តួចផ្តើម សហការ ផ្សព្វផ្សាយ ចែករំលែក ដោះដូរ ចំណេះដឹង និងបទពិសោធន៍ រវាងបុគ្គលិកផ្នែកបណ្តុះបណ្តាលដូចគ្នា និងបុគ្គលដទៃទៀត ក្នុងមជ្ឈដ្ឋានអប់រំដើម្បីធានាបាននូវការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលប្រកបដោយស្តង់ដារ និងគុណភាព
- ផ្តល់សេវាក្នុងការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ ប្រកបដោយគរុកោសល្យ ស្របតាមមុខវិជ្ជា និងឯកទេសរបស់ខ្លួន ដោយគោរពតាមក្របខណ្ឌគុណវុឌ្ឍិជាតិ និង/ឬ វិជ្ជាជីវៈទេសចរណ៍ជាតិ និងអាស៊ាន ក៏ដូចជាកម្មវិធីបណ្តុះបណ្តាល ដែលត្រូវបានទទួលស្គាល់ ឬកំណត់ដោយក្រសួងទេសចរណ៍ និង/ឬ ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត សម្រាប់ការសិក្សាគ្រប់ទម្រង់ មិនថាជាការសិក្សាក្នុងថ្នាក់ តាមប្រព័ន្ធអនឡាញ និង/ឬជាការសិក្សាតាមមធ្យោបាយផ្សេងទៀត និង
- ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកម្មវិធីផ្សេងៗ តាមការអញ្ជើញរបស់ក្រសួងទេសចរណ៍ និង/ឬ ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត។

#### 2.2. ទំនាស់ផលប្រយោជន៍

- ផ្តល់ព័ត៌មានភ្លាមៗ ទាំងស្រុង និងមិនលាក់លៀមដល់សាលាបណ្តុះបណ្តាលក្នុងករណីមានទំនាស់ផលប្រយោជន៍ (ឧទាហរណ៍៖ ផលប្រយោជន៍ជាទឹកប្រាក់ ផលប្រយោជន៍នយោបាយ ផលប្រយោជន៍សម្រាប់គ្រួសារ ឬផលប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចមានឥទ្ធិពលលើទង្វើរបស់ជនណាម្នាក់ ក្នុងការអនុវត្តកាតព្វកិច្ចផ្លូវការរបស់ខ្លួន) ដែលអាចប៉ះពាល់ដល់ការបំពេញវិជ្ជាជីវៈដោយឯករាជ្យ និង
- យកចិត្តទុកដាក់ និងផ្តោតជាសំខាន់លើការអប់រំ ដោយជៀសវាងធ្វើអាជីវកម្ម ឬសកម្មភាពណាមួយដើម្បីបង្កើតឱ្យមានទំនាស់ផលប្រយោជន៍ នៅក្នុង ថ្នាក់រៀន ឬសាលាបណ្តុះបណ្តាល។

2.3. **ល្បែងស៊ីសង**

- មិនប្រព្រឹត្ត ឬបណ្ដាល/ជំរុញឱ្យមានការប្រព្រឹត្ត ល្បែងស៊ីសង និង
- រាយការណ៍មកសាលាបណ្ដុះបណ្ដាល នៅពេលមានការប្រព្រឹត្ត ឬសង្ស័យថាមានការប្រព្រឹត្ត ល្បែងស៊ីសង។

2.4. **គ្រឿងស្រវឹង ថ្នាំជក់ ផលិតផលថ្នាំជក់ អាវុធ ឬគ្រឿងញៀន**

- មិនប្រើប្រាស់ ឬបណ្ដាល/ជំរុញឱ្យមានការប្រើប្រាស់ គ្រឿងស្រវឹង ថ្នាំជក់ ផលិតផលថ្នាំជក់ អាវុធ ឬគ្រឿងញៀន និង
- រាយការណ៍មកសាលាបណ្ដុះបណ្ដាល នៅពេលមានការប្រើប្រាស់ ឬសង្ស័យថាមានការប្រើប្រាស់ គ្រឿងស្រវឹង ថ្នាំជក់ ផលិតផលថ្នាំជក់ អាវុធ ឬគ្រឿងញៀន ក្នុងសាលាបណ្ដុះបណ្ដាល។

2.5. **អត្ថប្រយោជន៍**

- មិនបង្ខិតបង្ខំ បញ្ចុះបញ្ចូល សិស្ស/សិក្ខាកាម ឬមាតាបិតា ឬធ្វើសកម្មភាពណាមួយ ដើម្បីទទួលបានអត្ថប្រយោជន៍ណាមួយ និង
- បដិសេធទទួលអត្ថប្រយោជន៍ពី សិស្ស/សិក្ខាកាម ឬមាតាបិតា និងត្រូវជូនដំណឹងមកសាលាបណ្ដុះបណ្ដាល លើកលែងតែអត្ថប្រយោជន៍នោះ ជាជំនូនតាមទំនៀមទម្លាប់ ឬប្រពៃណី ឬធ្វើឡើងក្នុងលក្ខខណ្ឌសមរម្យ ដែលមិនកើតឡើងពីកិច្ចព្រមព្រៀងណាមួយរវាងអ្នកឱ្យ និងអ្នកទទួល។

2.6. **ការចុះផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយ**

- មានការប្រុងប្រយ័ត្នខ្ពស់ ចំពោះការចុះផ្សាយណាមួយពីសាលាបណ្ដុះបណ្ដាល លើប្រព័ន្ធផ្សព្វផ្សាយ ឬបណ្ដាញសង្គមនានា ក៏ដូចជាការផ្ដល់ព័ត៌មានណាមួយពីសាលាបណ្ដុះបណ្ដាលដល់ប្រព័ន្ធផ្សព្វផ្សាយ ឬបណ្ដាញសង្គមនានា និង
- ចុះផ្សាយ ឬផ្ដល់ព័ត៌មានណាមួយពីសាលាបណ្ដុះបណ្ដាលទៅប្រព័ន្ធផ្សព្វផ្សាយ ឬបណ្ដាញសង្គមនានា តែនៅពេលមានការអនុញ្ញាតពីសាលាបណ្ដុះបណ្ដាល និងក្នុងខ្លឹមសារដែលឯកភាពគ្នាតែប៉ុណ្ណោះ។

2.7. **ការប្រើប្រាស់ធនធានរបស់សាលាបណ្ដុះបណ្ដាល**

- ប្រើប្រាស់ ធនធានរបស់សាលាបណ្ដុះបណ្ដាល (ដូចជា កុំព្យូទ័រ ទូរស័ព្ទ ប្រព័ន្ធ/សេវាទូរស័ព្ទ ប្រព័ន្ធ/សេវាអ៊ីនធឺណែត ទឹក ភ្លើង និងសម្ភារៈការិយាល័យ ដូចជា ប៊ិច ខ្មៅដៃ សៀវភៅ ឬក្រដាស) ដោយសន្សំសំចៃ និងសម្រាប់តែការបំពេញមុខនាទីរបស់ខ្លួនតែប៉ុណ្ណោះ និង
- មិនប្រើប្រាស់ធនធានរបស់សាលាបណ្ដុះបណ្ដាលដើម្បី បម្រើផលប្រយោជន៍ ឬសកម្មភាពផ្ទាល់ខ្លួន ឬ ប្រព្រឹត្តបទល្មើសណាមួយ (ឧទាហរណ៍៖ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតរបស់សាលាបណ្ដុះបណ្ដាល ដើម្បីមើលគេហទំព័រអាសអាភាស ឬប្រព្រឹត្តសកម្មភាពល្មើសច្បាប់ជាដើម)។

3. **ការសម្ងាត់វិជ្ជាជីវៈ**

លើកលែងតែមានការតម្រូវដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា បុគ្គលិកផ្នែកបណ្តុះបណ្តាលក្នុងគ្រប់កាលៈទេសៈទាំងអស់ ត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈចំពោះរាល់ ការពិភាក្សា ព័ត៌មាន និង/ឬឯកសារដែលទទួលបាននៅក្នុងពេលបំពេញមុខងាររបស់ខ្លួន មិនថាព័ត៌មាន និង/ឬឯកសារទាំងនោះបានមកពីសាលាបណ្តុះបណ្តាល ឬបុគ្គលណាម្នាក់ឡើយ ( ឧទាហរណ៍៖ បានមកពីសិស្ស/សិក្ខាកាម ឬមាតាបិតា )។ បុគ្គលិកផ្នែកបណ្តុះបណ្តាល មិនត្រូវបញ្ចេញ ឬបរិហារ ព័ត៌មាន និង/ឬឯកសារ ទៅបុគ្គលដទៃដោយមិនមានការអនុញ្ញាតទុកជាមុនពីម្ចាស់ព័ត៌មានឡើយ។

4. **ការរើសអើង**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវប្រកាន់ខ្ជាប់ ជំរុញ និងលើកកម្ពស់គោលការណ៍សមភាព និងការមិនរើសអើង។ ការអប់រំ ត្រូវធ្វើឡើងក្នុងគោលការណ៍សមភាព ប្រាសចាកពីគំនិតប្រកាន់ ទំនោរ ការរាប់អាន ឬការយកចិត្តទុកដាក់ជាពិសេសចំពោះសិស្ស/សិក្ខាកាម និង/ឬមាតាបិតា ណាម្នាក់ ឬក្រុមណាមួយ ដោយមិនមាន ការរើសអើងប្រកាន់ជាតិសាសន៍ ដើមកំណើត អាយុ ភេទ ពណ៌សម្បុរ ពិការភាព និន្នាការនយោបាយ ជំនឿ សាសនា ស្ថានភាពសេដ្ឋកិច្ច ឬឋានៈសង្គមណាមួយឡើយ។

5. **អព្យាក្រឹតភាព**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវប្រតិបត្តិវិជ្ជាជីវៈ ដោយអព្យាក្រឹត្យ ភាពជាកណ្តាល ដោយមិនរើសអើង មិនប្រកាន់បក្សពួក និន្នាការ នយោបាយ ឬជំនឿ សាសនាអ្វីឡើយ។

6. **ការកម្រិតសកម្មភាពផ្នែកនយោបាយ**

ទោះបីបុគ្គលិកផ្នែកបណ្តុះបណ្តាលមាន សេរីភាពបញ្ចេញមតិ និងសិទ្ធិនយោបាយក៏ដោយ ក៏បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវប្រើប្រាស់សិទ្ធិសេរីភាពទាំងនោះនៅក្នុងសាលាបណ្តុះបណ្តាលដោយមានការប្រុងប្រយ័ត្ន។ ពោលគឺ បុគ្គលិកផ្នែកបណ្តុះបណ្តាល មិនត្រូវតាមរយៈវេទិកា/មុខនាទីរបស់ខ្លួនក្នុងនាមជាអ្នកអប់រំ បង្ខិតបង្ខំ បញ្ចុះបញ្ចូល ផ្សព្វផ្សាយ ឃោសនា បញ្ចេញមតិ ចែករំលែក ឬបង្ហាញ ទស្សនៈ ឬនិន្នាការនយោបាយ របស់ខ្លួន មិនថាដល់ សិស្ស/សិក្ខាកាម ឬបុគ្គលណាម្នាក់ នៅក្នុងសាលាបណ្តុះបណ្តាល។

7. **សិទ្ធិអ្នកនិពន្ធ និងកម្មសិទ្ធិបញ្ញា**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវជៀសវាងរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញារបស់អ្នកដទៃ មិនថាស្នាដៃដែលយកមកប្រើនោះ គឺជាស្នាដៃបោះពុម្ព ស្នាដៃជា រូបភាព ឬសម្លេង ការបង្កើតថ្មី ឬការស្រាវជ្រាវជាដើម ដើម្បីបំពេញសកម្មភាពវិជ្ជាជីវៈរបស់ខ្លួន ( ឧទាហរណ៍៖ ដើម្បីកែសម្រួល បង្កើត ឬអភិវឌ្ឍជាកម្មវិធីអប់រំបណ្តុះបណ្តាល កិច្ចតែងការបង្រៀន ឬឯកសារមេរៀនរបស់សាលាបណ្តុះបណ្តាលជាដើម )។

8. **ការមិនប្រព្រឹត្តអំពើពុករលួយ**

មិនថាក្នុងរូបភាពណាក៏ដោយ បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវ៖

- មិនប្រព្រឹត្ត ឬបណ្តាល/ជំរុញឱ្យមាន ការស៊ីសំណូក ការសូកប៉ាន់ ឬអំពើពុករលួយផ្សេងទៀត និង
- រាយការណ៍មកសាលាបណ្តុះបណ្តាល នៅពេលមាន ឬសង្ស័យថាមាន ការស៊ីសំណូក ការសូកប៉ាន់ ឬអំពើពុករលួយផ្សេងទៀត ក្នុងសាលាបណ្តុះបណ្តាល។

9. **ការគំរាមកំហែង អំពើហិង្សា ឬការពុករលួយ**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវ៖

- មិន គំរាមកំហែង ប្រព្រឹត្តអំពើហិង្សា ឬធ្វើការរុករក ផ្លូវចិត្ត ផ្លូវកាយ ឬផ្លូវភេទ ដល់បុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈរបស់ខ្លួន ឬបណ្តាល/ជំរុញឱ្យមានសកម្មភាពណាមួយក្នុងចំណោមនោះ និង
- រាយការណ៍មកសាលាបណ្តុះបណ្តាល នៅពេលមានការគំរាមកំហែង អំពើហិង្សា ការរុករក ឬសង្ស័យថាមានអំពើណាមួយក្នុងចំណោមនោះក្នុងសាលាបណ្តុះបណ្តាល។

10. **អំពើល្មើសផ្សេងទៀត**

បុគ្គលិកផ្នែកបណ្តុះបណ្តាល ត្រូវ៖

- មិនប្រព្រឹត្ត ឬបណ្តាល/ជំរុញឱ្យមាន អំពើល្មើសច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- រាយការណ៍មកសាលាបណ្តុះបណ្តាល នៅពេលមាន ឬសង្ស័យថាមាន អំពើល្មើសច្បាប់ក្នុងសាលាបណ្តុះបណ្តាល និង
- ជូនដំណឹងមកកាន់សាលាបណ្តុះបណ្តាលជាបន្ទាន់ នៅពេលមានការប្តឹងផ្តល់ ឬបានប្រព្រឹត្តអំពើ ល្មើសណាមួយ ទោះដោយចេតនា ឬអចេតនា ឬនៅពេលមានការសម្រេច ដោយអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការអំពីទោស កំហុសរបស់ខ្លួន។

# ឧបសម្ព័ន្ធទី ២៖ ក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ
# សម្រាប់បុគ្គលិកផ្នែកផ្សេង

## ផ្នែក ក៖ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិកផ្នែកផ្សេង

---

### 1. គោលបំណង

ក្រមសីលធម៌វិជ្ជាជីវៈនេះ មានគោលបំណងកំណត់ និងណែនាំអំពីគោលការណ៍ជាគុណតម្លៃស្នូល ដែលជាមូលដ្ឋានគ្រឹះនៃអត្តចរិត ការសម្រេចចិត្ត សកម្មភាព ការរៀបចំបុគ្គលិកលក្ខណៈ និងការសំដែងអាកប្បកិរិយាប្រកបដោយសីលធម៌វិជ្ជាជីវៈ ក្នុងគោលដៅលើកកម្ពស់តម្លៃបុគ្គល និងវិជ្ជាជីវៈក្នុងនាមជាបុគ្គលិកដែលស្ថិតក្នុងវិស័យអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍។

### 2. គោលការណ៍ជាគុណតម្លៃស្នូល

#### 2.1. សមភាព

បុគ្គលិកផ្នែកផ្សេង ត្រូវបង្ហាញ **សមភាព** តាមរយៈការផ្តល់តម្លៃស្មើៗគ្នាចំពោះបុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈរបស់ខ្លួន ក៏ដូចជាចូលរួមបង្កើតបរិយាកាសសមភាពក្នុងមជ្ឈដ្ឋានអប់រំ ដោយមិនមានការរើសអើងណាមួយឡើយ។

#### 2.2. សុចរិតភាព

បុគ្គលិកផ្នែកផ្សេង ត្រូវបង្ហាញ **សុចរិតភាព** តាមរយៈ៖

- ភាពស្មោះត្រង់ ទង្វើត្រឹមត្រូវ និងការប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ និងតម្លាភាព ក្នុងការបំពេញវិជ្ជាជីវៈ
- ការកសាងទំនុកចិត្ត ក្នុងទំនាក់ទំនងជាមួយបុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈ និង
- ឆន្ទៈដ៏រឹងមាំ និងមិនងាករេ ក្នុងការផ្សារភ្ជាប់ខ្លួននឹងគោលការណ៍ និងគុណតម្លៃនៃសីលធម៌វិជ្ជាជីវៈ ក៏ដូចជាការប្រកាន់ជំហរក្នុងការអនុវត្តតាម និងលើកតម្កើងជាដរាបនូវគោលការណ៍ និងគុណតម្លៃនៃសីលធម៌វិជ្ជាជីវៈក្នុងគ្រប់កាលៈទេសៈទាំងអស់។

#### 2.3. គណនេយ្យភាព

បុគ្គលិកផ្នែកផ្សេង ត្រូវបង្ហាញ **គណនេយ្យភាព** តាមរយៈ ភាពម្ចាស់ការលើផែនការ/គោលដៅសកម្មភាព រួមមានការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងចេញមុខទទួលខុសត្រូវ ចំពោះផែនការ/គោលដៅសកម្មភាពរបស់ខ្លួន និងលទ្ធផលរបស់វា មិនថាជាលទ្ធផលល្អ ឬអាក្រក់។

#### 2.4. ឯករាជ្យភាព និងភាពមិនលម្អៀង

បុគ្គលិកផ្នែកផ្សេង ត្រូវបង្ហាញ **ឯករាជ្យភាព និងភាពមិនលម្អៀង** តាមរយៈ ការបំពេញសកម្មភាពវិជ្ជាជីវៈ និងការវិនិច្ឆ័យ ដោយតម្លាភាព មិនមានការវិនិច្ឆ័យទុកជាមុនណាមួយ ឬឥទ្ធិពលពីកត្តា ហេតុការណ៍ ឬបុគ្គលណាម្នាក់។

#### 2.5. ការគោរពចំពោះអ្នកដទៃ

បុគ្គលិកផ្នែកផ្សេង ត្រូវបង្ហាញ **ការគោរពចំពោះអ្នកដទៃ** មិនថាជាពាក្យសំដី ឬសកម្មភាព តាមរយៈការឱ្យតម្លៃគ្នាទៅវិញទៅមក និងការប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ ក្នុងទំនាក់ទំនងជាមួយ បុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈ។

3. **ការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវវិជ្ជាជីវៈ**

3.1. ដោយឈរលើគោលការណ៍សមភាព សុចរិតភាព គណនេយ្យភាព ឯករាជ្យភាព និងភាពមិនលម្អៀង និង ការគោរពចំពោះអ្នកដទៃ បុគ្គលិកផ្នែកផ្សេង ត្រូវមានការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវវិជ្ជាជីវៈចំពោះ៖

- សិស្ស/សិក្ខាកាម
- មាតាបិតា
- សហគមន៍
- បុគ្គលិកសាលាបណ្តុះបណ្តាល និង
- សាលាបណ្តុះបណ្តាល។

3.2. បុគ្គលិកផ្នែកផ្សេង ត្រូវឈរលើស្មារតីយោគយល់ អត់ឱន និងសាមគ្គីភាព ដើម្បីសម្រុះសម្រួល និងដោះស្រាយដោយសន្តិវិធី ក្នុងករណីមានជម្លោះ។

## ផ្នែក ៩៖ ក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់បុគ្គលិកផ្នែកផ្សេង

---

### 1. គោលបំណង

ក្រមប្រតិបត្តិវិជ្ជាជីវៈនេះ មានគោលបំណងកំណត់ និងណែនាំអំពីស្តង់ដារសកម្មភាពជាមូលដ្ឋាន ដែលបុគ្គលិកផ្សេងទៀតរបស់សាលាបណ្តុះបណ្តាល ត្រូវជៀសវាង និងអនុវត្តឱ្យបានខ្ជាប់ខ្ជួនក្នុងសកម្មភាពវិជ្ជាជីវៈ ក្នុងគោលដៅលើកកម្ពស់តម្លៃវិជ្ជាជីវៈ ក៏ដូចជាស្តង់ដារ និងគុណភាពការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍របស់សាលាបណ្តុះបណ្តាល។

### 2. ភាពស័ក្តិសមសម្រាប់វិជ្ជាជីវៈ

បន្ថែមពីលើសមត្ថភាពស្នូល (core competencies) បុគ្គលិកផ្នែកផ្សេង ត្រូវធ្វើខ្លួនជាបុគ្គលដ៏ប្រពៃ និងគំរូល្អនៅក្នុងសាលាបណ្តុះបណ្តាល មិនថាតាមរយៈពាក្យសំដី សកម្មភាព ឬការស្លៀកពាក់ ដោយជានិច្ចកាលត្រូវ៖

#### 2.1. ចំណេះ និងជំនាញ

- បន្តស្វ័យសិក្សា ពង្រីកចំណេះដឹង និងពង្រឹងសមត្ថភាព ផ្តួចផ្តើម សហការ ផ្សព្វផ្សាយ ចែករំលែក ដោះដូរ ចំណេះដឹង និងបទពិសោធន៍ រវាងបុគ្គលិកពាក់ព័ន្ធនឹងវិជ្ជាជីវៈ។

#### 2.2. អត្ថប្រយោជន៍

- មិនស្វែងរក បញ្ចុះបញ្ចូល ឬបង្ខិតបង្ខំបុគ្គលណាម្នាក់ ឬធ្វើសកម្មភាពណាមួយ ដើម្បីទទួលបានអត្ថប្រយោជន៍ណាមួយ និង
- បដិសេធទទួលអត្ថប្រយោជន៍ពី សិស្ស/សិក្ខាកាម ឬមាតាបិតា និងត្រូវជូនដំណឹងមកសាលាបណ្តុះបណ្តាល លើកលែងតែអត្ថប្រយោជន៍នោះ ជាជំនូនតាមទំនៀមទម្លាប់ ឬប្រពៃណី ឬធ្វើឡើងក្នុងលក្ខខណ្ឌសមរម្យ ដែលមិនកើតឡើងពីកិច្ចព្រមព្រៀងណាមួយរវាងអ្នកឱ្យ និងអ្នកទទួល។

#### 2.3. ការចុះផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយ

- ចុះផ្សាយលើ ឬផ្តល់ព័ត៌មាន ឬការសម្រេចណាមួយរបស់សាលាបណ្តុះបណ្តាលទៅ ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញសង្គមនានា តែនៅពេលមានការអនុញ្ញាតពីសាលាបណ្តុះបណ្តាល និងក្នុងខ្លឹមសារដែលឯកភាពគ្នាតែប៉ុណ្ណោះ។

#### 2.4. ការប្រើប្រាស់ធនធានរបស់សាលាបណ្តុះបណ្តាល

- ប្រើប្រាស់ធនធានរបស់សាលាបណ្តុះបណ្តាល (ដូចជា កុំព្យូទ័រ ទូរស័ព្ទ ប្រព័ន្ធសារទូរស័ព្ទ ប្រព័ន្ធ/សេវាអ៊ីនធើណែត ទឹក ភ្លើង និងសម្ភារៈការិយាល័យ ដូចជា ប៊ិច ខ្មៅដៃ សៀវភៅ ឬក្រដាស) ដោយសន្សំសំចៃ និងសម្រាប់តែការបំពេញមុខនាទីរបស់ខ្លួនតែប៉ុណ្ណោះ និង
- មិនប្រើប្រាស់ធនធានរបស់សាលាបណ្តុះបណ្តាលដើម្បី បម្រើផលប្រយោជន៍ ឬសកម្មភាពផ្ទាល់ខ្លួន ឬប្រព្រឹត្តបទល្មើសណាមួយ (ឧទាហរណ៍៖ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណែតរបស់សាលាបណ្តុះបណ្តាល ដើម្បីឆែកមើលគេហទំព័រអាសអាភាស ឬប្រព្រឹត្តសកម្មភាពល្មើសច្បាប់ជាដើម)។

3. **ការសម្ងាត់វិជ្ជាជីវៈ**

លើកលែងតែមានការតម្រូវដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា បុគ្គលិកផ្នែកផ្សេងក្នុងគ្រប់កាលៈទេសៈទាំងអស់ ត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈចំពោះរាល់ ការពិភាក្សា ព័ត៌មាន និង/ឬឯកសារដែលទទួលបាននៅក្នុងពេលបំពេញមុខងាររបស់ខ្លួន។ បុគ្គលិកផ្នែកផ្សេង មិនត្រូវបញ្ចេញ ឬបរិហារ ព័ត៌មាន និង/ឬឯកសារ ទៅបុគ្គលដទៃ ដោយមិនមានការអនុញ្ញាតទុកជាមុនពីម្ចាស់ព័ត៌មានឡើយ។

4. **ការរើសអើង**

បុគ្គលិកផ្នែកផ្សេង មិនត្រូវមាន ការរើសអើង ប្រកាន់ជាតិសាសន៍ ដើមកំណើត អាយុ ភេទ ពណ៌សម្បុរ ពិការភាព និន្នាការនយោបាយ ជំនឿ សាសនា ស្ថានភាពសេដ្ឋកិច្ច ឬឋានៈសង្គម នៅពេលបំពេញតួនាទីរបស់ខ្លួន។ បុគ្គលិកផ្នែកផ្សេង ត្រូវប្រកាន់ខ្ជាប់ ជំរុញ និងលើកកម្ពស់ គោលការណ៍សមភាព និងការមិនរើសអើង។

5. **អព្យាក្រឹតភាព**

បុគ្គលិកផ្នែកផ្សេង ត្រូវប្រតិបត្តិវិជ្ជាជីវៈ ដោយអព្យាក្រឹត្យ ភាពជាកណ្តាល ដោយមិនរើសអើង មិនប្រកាន់បក្សពួក និន្នាការនយោបាយ ឬជំនឿ សាសនាអ្វីឡើយ។

6. **ការហាមឃាត់សកម្មភាពផ្នែកនយោបាយ**

បុគ្គលិកផ្នែកផ្សេង មិនត្រូវ បង្ខិតបង្ខំ បញ្ចុះបញ្ចូល ផ្សព្វផ្សាយ ឃោសនា បញ្ចេញមតិ ចែករំលែក ឬបង្ហាញទស្សនៈ ឬនិន្នាការនយោបាយរបស់ខ្លួនដល់បុគ្គលណាម្នាក់នៅក្នុងសាលាបណ្តុះបណ្តាលឡើយ។

7. **អំពើល្មើសច្បាប់**

បុគ្គលិកផ្នែកផ្សេង ត្រូវ៖

- មិនប្រព្រឹត្តអំពើល្មើសច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ដូចជាការប្រព្រឹត្តល្បែងស៊ីសង ការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំញៀន ផលិតផលថ្នាំជក់ អាវុធ ឬគ្រឿងផ្ទុះ ប្រពឹត្តអំពើស៊ីសំណូកសូកប៉ាន់ ឬអំពើពុករលួយ អំពើគំរាមកំហែង អំពើហិង្សា ឬការជួញដូរ ផ្លូវចិត្ត ផ្លូវកាយ ឬផ្លូវភេទ ដល់បុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈរបស់ខ្លួន ឬបណ្តាល/ជំរុញឱ្យមានអំពើល្មើសណាមួយ
- រាយការណ៍មកសាលាបណ្តុះបណ្តាល នៅពេលមាន ឬសង្ស័យថាមាន អំពើល្មើសច្បាប់ក្នុងសាលាបណ្តុះបណ្តាល និង
- ជូនដំណឹងមកកាន់សាលាបណ្តុះបណ្តាលជាបន្ទាន់ នៅពេលមានការប្តឹងផ្តល់ ឬបានប្រព្រឹត្តអំពើល្មើសណាមួយ ទោះដោយចេតនា ឬអចេតនា ឬនៅពេលមានការសម្រេច ដោយអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ អំពីទោសកំហុសរបស់ខ្លួន។

# ឧបសម្ព័ន្ធទី ៣៖ វាក្យសព្ទ

| | | | |
|---|---|---|---|
| 1. | ក្រម | ៖ | សំដៅដល់ក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់បុគ្គលិកផ្នែកបណ្ដុះបណ្ដាល និងសម្រាប់បុគ្គលិកផ្នែកផ្សេង។ |
| 2. | ក្រមសីលធម៌វិជ្ជាជីវៈ និង/ ឬក្រមប្រតិបត្តិវិជ្ជាជីវៈ កំណត់ដោយច្បាប់ | ៖ | សំដៅដល់ក្រមសីលធម៌វិជ្ជាជីវៈ និង/ឬក្រមប្រតិបត្តិវិជ្ជាជីវៈ បង្កើតឡើងដោយច្បាប់ជាធរមាន ដែលមានសុពលភាពគតិយុត្ត និងវិសាលភាពអនុវត្តលើបុគ្គលិកផ្នែកបណ្ដុះបណ្ដាល និង/ឬបុគ្គលិកផ្នែកផ្សេង ឬបុគ្គលិកសាលាបណ្ដុះបណ្ដាល។ |
| 3. | ការសូកប៉ាន់ | ៖ | សំដៅដល់ ការប្រគល់ ការសន្យាប្រគល់ ឬការយល់ព្រមឱ្យ អត្ថប្រយោជន៍ណាមួយ ដើម្បីឱ្យជនណាម្នាក់បំពេញ ឬមិនបំពេញកិច្ចអ្វីមួយក្នុងមុខងាររបស់ជននោះ។ |
| 4. | ការស៊ីសំណូក | ៖ | សំដៅដល់ ការសុំ ឬការយល់ព្រមទទួល អត្ថប្រយោជន៍ណាមួយ ដើម្បីជាថ្នូរនៃការបំពេញ ឬមិនបំពេញកិច្ចអ្វីមួយក្នុងមុខងាររបស់ខ្លួន។ |
| 5. | សាលាបណ្ដុះបណ្ដាល | ៖ | សំដៅដល់ ឈ្មោះគ្រឹះស្ថានបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍។ |
| 6. | មាតាបិតា | ៖ | សំដៅដល់ឪពុក និង/ឬម្ដាយបង្កើត ឬអាណាព្យាបាលស្របច្បាប់របស់សិស្ស/សិក្ខាកាមម្នាក់ៗ។ |
| 7. | បុគ្គលិកសាលាបណ្ដុះបណ្ដាល | ៖ | សំដៅដល់បុគ្គលិកទាំងអស់របស់សាលាបណ្ដុះបណ្ដាល ដែលរួមមានបុគ្គលិកផ្នែកបណ្ដុះបណ្ដាល និងបុគ្គលិកផ្នែកផ្សេង។ |
| 8. | បុគ្គលិកផ្នែកបណ្ដុះបណ្ដាល | ៖ | សំដៅដល់ គ្រូបង្គោល គ្រូជំនួយ ផ្នែកអប់រំបណ្ដុះបណ្ដាលជំនាញទេសចរណ៍ ដែលអាចជាបុគ្គលិកស្ថិតក្នុងដំណាក់កាលសាកល្បងការងារ ឬជាបុគ្គលិកពេញសិទ្ធិ ឬបុគ្គលិកស្ម័គ្រចិត្ត មិនថាសម្រាប់រយៈពេលវែង ឬខ្លី រួមបញ្ចូលទាំងនាយកសាលា (principal) និងគណៈគ្រប់គ្រង (management board) របស់សាលាបណ្ដុះបណ្ដាលផងដែរ។ |
| 9. | បុគ្គលិកផ្នែកផ្សេង | ៖ | សំដៅដល់បុគ្គលិកផ្នែកផ្សេងរបស់សាលាបណ្ដុះបណ្ដាល ដែលមិនមែនជាបុគ្គលិកផ្នែកបណ្ដុះបណ្ដាល ដែលអាចជាបុគ្គលិកស្ថិតក្នុងដំណាក់កាលសាកល្បងការងារ ឬជាបុគ្គលិកពេញសិទ្ធិ ឬបុគ្គលិកស្ម័គ្រចិត្ត មិនថាសម្រាប់រយៈពេលវែង ឬខ្លី។ |
| 10. | បុគ្គលពាក់ព័ន្ធនឹងវិជ្ជាជីវៈ | ៖ | សំដៅដល់ សិស្ស/សិក្ខាកាម មាតាបិតា បុគ្គលិកផ្នែកបណ្ដុះបណ្ដាល បុគ្គលិកផ្នែកផ្សេង និងបុគ្គលដទៃទៀតក្នុងមជ្ឈដ្ឋានអប់រំ។ |
| 11. | សិស្ស/សិក្ខាកាម | ៖ | សំដៅដល់ សិស្ស និងសិក្ខាកាមទាំងអស់នៃផ្នែកអប់រំបណ្ដុះបណ្ដាលជំនាញទេសចរណ៍របស់សាលាបណ្ដុះបណ្ដាល។ |
| 12. | អត្ថប្រយោជន៍ | ៖ | (ក) អំណោយអ្វីមួយ កម្ចី តម្លៃឈ្នួល រង្វាន់ ឬកម្រៃជើងសារ ដែលមិនមានការអនុញ្ញាតដោយច្បាប់ជាធរមាន ជាទឹកប្រាក់ ឬជាវត្ថុមានតម្លៃ ឬជាទ្រព្យសម្បត្តិប្រភេទអ្វីមួយ។<br>(ខ) ការងារ តំណែង មុខងារ កិច្ចព្រមព្រៀង ឬកិច្ចសន្យាអ្វីមួយ។ |

(គ) ការបង់ប្រាក់ ការលើកលែង ការលុបចោល ការលុបបំបាត់នូវប្រាក់កម្ចីអ្វីមួយ កាតព្វកិច្ច ឬបំណុលផ្សេងទៀត ទោះជាទាំងមូលក្តី ឬដោយផ្នែកក្តី។

(ឃ) សេវាកម្មឯទៀត ឬការផ្តល់ជាគុណប្រយោជន៍ រួមទាំងកិច្ចការពារមិនឱ្យមានការដាក់ទណ្ឌកម្ម ដែលលេចចេញពីអំពើ ឬដំណើរការនៃការដាក់ទណ្ឌកម្មរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ទោះបីទណ្ឌកម្មនេះ ត្រូវបានកំណត់ ឬពុំទាន់ត្រូវបានកំណត់ក៏ដោយ។

(ង) ការអនុវត្ត ឬការរាំងមិនឱ្យអនុវត្តនូវសិទ្ធិ ឬអំណាច ឬភារកិច្ចអ្វីមួយ។

(ច) ការស្នើជូន ឬការសន្យាថាជូន ទោះបីមានលក្ខខណ្ឌ ឬគ្មានលក្ខខណ្ឌក្តី នូវប្រយោជន៍ ដូចមានចែងក្នុងស្មារតីនៃកថាខណ្ឌ (ក) (ខ) (គ) (ឃ) និង (ង) ខាងលើ។

13. អំពើពុករលួយ : សំដៅដល់បទល្មើសព្រហ្មទណ្ឌ ដែលមានចែងក្នុងជំពូកទី ៦ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០១០ រួមមាន ការសូកប៉ាន់ ការស៊ីសំណូក (រៀងគ្នាជាអំពើពុករលួយក្នុងទម្រង់សកម្ម និងអកម្ម) ឬអំពើពុករលួយផ្សេងទៀត។

## ឧបសម្ព័ន្ធទី ៩៖ តំណភ្ជាប់

1. តំណភ្ជាប់ទៅក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់បុគ្គលិកផ្នែកបណ្តុះបណ្តាល៖ សម្រាប់ដាក់តំណភ្ជាប់ (ប្រសិនបើមាន)។
2. តំណភ្ជាប់ទៅក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់បុគ្គលិកផ្នែកផ្សេង៖ សម្រាប់ដាក់តំណភ្ជាប់ (ប្រសិនបើមាន)។
3. តំណភ្ជាប់ទៅឯកសារយោងផ្សេងទៀត៖
   - តំណភ្ជាប់ទៅក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន នៃអនុក្រឹត្យលេខ ១២៦ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨ចេញដោយរាជរដ្ឋាភិបាលកម្ពុជា៖ សម្រាប់ដាក់តំណភ្ជាប់ (ប្រសិនបើមាន)
   - តំណភ្ជាប់ទៅគោលការណ៍ប្រតិបត្តិស្តង់ដារ (SOP) សម្រាប់ដំណើរការសាលារៀនឡើងវិញក្នុងបរិបទកូវីដ-១៩ ចេញដោយក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០៖ សម្រាប់ដាក់តំណភ្ជាប់ (ប្រសិនបើមាន)
   - តំណភ្ជាប់ទៅសេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា សម្រាប់ដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃក្នុងគន្លងប្រក្រតីភាពថ្មី ចេញដោយក្រសួងទេសចរណ៍ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១៖ សម្រាប់ដាក់តំណភ្ជាប់ (ប្រសិនបើមាន) និង
   - តំណភ្ជាប់ទៅគោលការណ៍ប្រតិបត្តិស្តង់ដារ (SOP) សម្រាប់ដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ឡើងវិញក្នុងបរិបទកូវីដ-១៩ ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១៖ សម្រាប់ដាក់តំណភ្ជាប់ (ប្រសិនបើមាន)។